ឯកសារស្រាវជ្រាវសង្ខេប

គណៈកម្មការទី២ ព្រឹទ្ធសភាទទួលបន្ទុក សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

# ការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់សេវាកម្ម របស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងខេត្តបាត់ដំបង

ស្រាវជ្រាវដោយៈ លោកស្រី គុប ដារី
ដឹកនាំដោយៈ លោក សូ សុវណ្ណារិទ្ធិ

ខែវិច្ឆិកា ឆ្នាំ២០១៦

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែល ផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការ ផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញ របស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬតួនាទីភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯក-សារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពី ទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពី វិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា


**១. សេចក្តីផ្តើម** .......................................................................................... 1

**២. ការអភិវឌ្ឍសេដ្ឋកិច្ច**.......................................................................................... 1

២.១. ការងារមនុស្សពេញវ័យ ដែលមានអាយុ១៨ឆ្នាំ ឡើង ............................................2

២.២. សក្តានុពលនៃការបង្កើនផលិតកម្មកសិកម្ម............................................................4

២.៣. កត្តាអំណោយផលសម្រាប់ទាក់ទាញការវិនិយោគ .................................................5

២.៤. កត្តាប្រឈមដែលផលិតករក្នុងស្រុកជួបប្រទះ ........................................................6

២.៥. គោលនយោបាយឆ្លើយតបនៅក្នុងបរិបទនៃដំណើរការអភិវឌ្ឍន៍ និងវិមជ្ឈការ......7

២.៦.ការពង្រឹងតួនាទីនៃរដ្ឋាភិបាលថ្នាក់ក្រោមជាតិ .......................................................10

**៣. ជម្រើសគោលនយោបាយ**.......................................................................................... 12

**ឯកសារយោង**.......................................................................................... 17

# ១. សេចក្តីផ្តើម

គណៈកម្មការទី២ព្រឹទ្ធសភាទទួលបន្ទុក សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដោយមានការចូលរួមពីគណៈកម្មការទី៨ ព្រឹទ្ធសភា នឹងមានកិច្ចប្រជុំជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន អភិបាលខេត្ត នាយកដ្ឋានបច្ចេកទេសថ្នាក់ខេត្តដែលពាក់ពន្ធ័ និងក្រុមប្រឹក្សាឃុំ ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី ១១ ខែវិច្ឆិការ ឆ្នាំ ២០១៦ នៅខេត្តបាត់ដំបង។ ឯកសារស្រាវជ្រាវសង្ខេបនេះ គឺរៀបចំឡើងដើម្បីផ្តល់នូវព័ត៌មានសម្រាប់បេសកម្មនេះ។ ឯកសារនេះផ្តោតលើតួនាទីរបស់រាជរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច។ ឯកសារស្រាវជ្រាវសង្ខេប នឹងឆ្លើយសំណួរស្រាវជ្រាវដូចខាងក្រោម៖

១. សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច៖ តើមានសកម្មភាពសេដ្ឋកិច្ច និងបញ្ហាប្រឈមចម្បងៗអ្វីខ្លះដែលប្រជាជននៅមូលដ្ឋានមាន និងបានជួបប្រទះនៅក្នុងខេត្តបាត់ដំបង?

២. សម្រាប់ការផ្តល់សេវាសាធារណៈ៖ តើសេវាសាធារណៈអ្វីខ្លះដែលបានផ្តល់ជូនដល់ប្រជាជននៅមូលដ្ឋាន សម្រាប់ដោះស្រាយបញ្ហាប្រឈម ដើម្បីធានាចីរភាពនៃសកម្មភាពសេដ្ឋកិច្ច និងសកម្មភាពរកប្រាក់ចំណូលរបស់ពួកគេ នៅក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងខេត្តបាត់ដំបង?

៣.តើមានជម្រើសគោលនយោបាយអ្វីខ្លះ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រជាជននៅក្នុងខេត្តបាត់ដំបង?

របកគំហើញដែលពិភាក្សាក្នុងអត្ថបទនេះ បានមកពីឯកសារស្រាវជ្រាវដែលមានស្រាប់ របាយការណ៍រដ្ឋាភិបាលនិងការវិភាគទិន្នន័យដែលមានស្រាប់ព្រមទាំងព័ត៌មានដែលអាចរកបានពីប្រព័ន្ធអ៊ិនធឺណិត។

# ២. ការអភិវឌ្ឍសេដ្ឋកិច្ច

យោងលើទិន្នន័យឃុំ ឆ្នាំ ២០១៥ បាត់ដំបងមានប្រជាជនចំនួន ១,២០៥,០៥០ នាក់ ឬប្រហែលជា ៨ % នៃចំនួនប្រជាជនកម្ពុជាសរុប (១៥,៤៧៧,៤២២ នាក់) ក្នុងឆ្នាំ ២០១៥ និង ជាខេត្តដែលធំជាងគេទីបី បន្ទាប់ពីរាជធានីភ្នំពេញ និងខេត្តកណ្តាល។[1] បាត់ដំបងជាតំបន់ឈានមុខគេខាងផលិកម្មស្រូវ។ ទោះបីជា កសិករជាច្រើនរងផលប៉ះពាល់ពីភាពមិនប្រក្រតីនៃអាកាសធាតុកពីរបីឆ្នាំចុងឆ្នាំចុងក្រោយនេះក៏ដោយ ក៏ខេត្តនេះផលិតស្រូវសរុបបាន ៧១៣,៧៤៧ តោន ឬប្រមាណប្រហែល ១១% នៃផលិតផលស្រូវកម្ពុជាក្នុងឆ្នាំ២០១៥ ដែលជាខេត្តធំទីបីក្នុងផលិកម្មស្រូវ បន្ទាប់ពីខេត្តព្រៃវែង និងតាកែវ (ឧបសម្ពន្ធ ១)។ ផែនទី១ បង្ហាញពីចំនួនភាគរយនៃផ្ទៃដីដាំដុះដំណាំស្រូវ និងចំការ តាមស្រុក

នីមួយៗនៃខេត្តបាត់ដំបងក្នុងឆ្នាំ ២០១៥។ ផែនទីនេះបង្ហាញថាស្រុកខ្លះក្នុងចំណោមស្រុកទាំង១៤ មិនពឹងផ្អែកលើផលិតកម្មស្រូវទាំងនោះទេ បើផ្អែកលើផ្ទៃដីដាំដុះ ។ ឧទាហរណ៍ ដំណាំចំការហាក់ជាប្រភពជីវភាពសំខាន់សម្រាប់ប្រជាជននៅស្រុក សំពៅលូន ភ្នំព្រឹក កំរៀង រតនមណ្ឌល និងសំឡូត ។

ផែនទី ១៖ ផ្ទៃដីប្រើប្រាស់សម្រាប់ដំណាំស្រូវ និងចំការ ក្នុងឆ្នាំ ២០១៥ ដោយយោងលើទិន្នន័យភូមិ ឃុំ ២០១៥ (យោងលើឧបសម្ព័ន្ធ២ សម្រាប់ការចាត់ថ្នាក់នៃសន្ទស្សន៍)




## *២.១. ការងារមនុស្សពេញវ័យ ដែលមានអាយុ១៨ឆ្នាំ ឡើង*

ទិន្នន័យឃុំ ២០១៥ បានបង្ហាញថា មនុស្សពេញវ័យមួយនាក់ គឺរ៉ាប់រងចិញ្ចឹមសមាជិកប្រហែលបីនាក់។ នៅក្នុងខេត្តនេះ គ្រួសារជាមធ្យមៗមានមនុស្សចំនួន ៤,៧ នាក់ ហើយក្នុងចំនោមស្រុកទាំងអស់នោះ ស្រុកបាត់ដំបងដែលមានធំហំគ្រួសារជាមធ្យមធំជាងគេ (តារាង១)។ តារាងទី១ បង្ហាញថា អត្រានៃអ្នកក្នុងបន្ទុកធំជាងគេ (អ្នករកចំណូលម្នាក់ត្រូវចិញ្ចឹមសមាជិកជិត ៦នាក់) មាននៅក្នុងស្រុកបវិល ។ តួរលេខនេះប្រហែលតម្រូវឲ្យមាន បទអន្តរាគមន៍នៃការកសាងផែនការគ្រួសារ ឬការពន្យាកំណើត ដើម្បីបង្កើនផលិតភាពការងារ ជាពិសេសស្ត្រី ដែលរស់នៅក្នុងស្រុកបវិល ។

តារាងទី១៖ ចំនួនប្រជាជន និងមុខរបរចម្បងរបស់មនុស្សពេញវ័យដែលមានអាយុ១៨ឆ្នាំ ឡើង តាមស្រុកនីមួយៗ ក្នុងឆ្នាំ ២០១៥

| | ចំនួនប្រជាជនសរុប | អត្រាក្នុងបន្ទុក | ទំហំគ្រួសារជាមធ្យម | មុខរបរចម្បង (ការងារសរុប) | ភាគរយនៃមុខរបរចម្បងតាមវិស័យ | | | |
|---|---|---|---|---|---|---|---|---|
| | | | | | កសិកម្ម | សេវាកម្ម | ធនធានធម្មជាតិ | សិប្បកម្ម/កែច្នៃ |
| រុក្ខគិរី | 52,351 | 2.6 | 4.9 | 19,807 | 88% | 12% | 1% | 0% |
| ភ្នំព្រឹក | 64,283 | 2.5 | 4.6 | 25,908 | 83% | 16% | 0% | 0% |
| រតនមណ្ឌល | 44,014 | 2.5 | 4.5 | 17,852 | 83% | 15% | 2% | 0% |
| កំរៀង | 59,634 | 2.2 | 4.4 | 26,888 | 82% | 17% | 1% | 0% |
| មោងឫស្សី | 126,716 | 2.5 | 4.6 | 51,191 | 81% | 18% | 1% | 0% |
| សំឡូត | 46,943 | 2.2 | 4.2 | 21,206 | 81% | 17% | 2% | 0% |
| បាណន់ | 109,319 | 2.5 | 4.7 | 43,307 | 80% | 18% | 2% | 0% |
| សង្កែ | 129,870 | 2.6 | 4.8 | 50,379 | 77% | 18% | 5% | 0% |
| សំពៅលូន | 47,388 | 2.6 | 4.7 | 17,988 | 76% | 19% | 2% | 2% |
| គាស់ក្រឡ | 37,585 | 2.7 | 5.1 | 13,777 | 76% | 21% | 3% | 0% |
| ថ្មគោល | 133,859 | 2.7 | 4.7 | 48,756 | 74% | 24% | 2% | 0% |
| បវិល | 114,902 | 5.6 | 3.9 | 20,484 | 68% | 23% | 9% | 0% |
| ឯកភ្នំ | 82,602 | 2.8 | 4.5 | 29,516 | 50% | **27%** | **23%** | 0% |
| បាត់ដំបង | 155,584 | 3.3 | 5.4 | 47,488 | 26% | **71%** | 1% | 2% |
| ស្រុកទាំងអស់ | 1,205,050 | 2.8 | 4.7 | 434,547 | 71% | 25% | 4% | 0% |

ប្រភព៖ ទិន្នន័យឃុំ ២០១៥ ក្រសួងផែនការ

តារាងទី១ ក៏បង្ហាញផងដែរថាវិស័យកសិកម្មក្នុងខេត្តបាត់ដំបងស្រូបយកកម្លាំងពលកម្មប្រហែល ៧១% និង បន្ទាប់មកគឺវិស័យសេវាកម្ម (២៥%)។ ចំនួនប្រជាជន (២៣%) ច្រើនជាងគេនៃស្រុកឯកភ្នំនៅពឹងផ្អែកលើធនធាន (ការនេសាទ អនុផលព្រៃឈើ និងការបរបាញ់) ជាមុខរបរចម្បងសំរាប់ចិញ្ចឹមជីវិត។ ភាពខុសគ្នាគួរឲ្យកត់សម្គាលនោះ គឺមាននៅស្រុកបាត់ដំបងដែលប្រជាជន ៧១% កំពុងប្រកបរបរចិញ្ចឹមជីវិតក្នុងវិស័យសេវាកម្ម ហើយមានតែ ២៦% ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ថាការធ្វើកសិកម្មជារបរចម្បង។ ការកែច្នៃចំណីអាហារ និងសិប្បកម្មនានា (ឧស្សាហកម្មជនបទ) ទាមទារឲ្យមានការគាំទ្រពីបទអន្តរាគមន៍អភិវឌ្ឍន៍ សំដៅលើកស្ទួយវិស័យឧស្សាហកម្មជនបទនេះ ដើម្បីលើកែលម្អ ចង្វាក់ផលិតកម្ម និងបង្កើតការងារថែមទៀតដល់អ្នកដែលទើបចូលទីផ្សារពលកម្មថ្មីនៅក្នុងខេត្តនេះ។[2]

## ២.២. សក្តានុពលនៃការបង្កើនផលិតកម្មកសិកម្ម

ផ្ទៃដីដាំដុះបានកើនឡើងប្រហែល ៤២% ពី ៤២៤,៤៥៩ហិចតា ក្នុងឆ្នាំ ២០១០/២០១១ ទៅ ៦០៦,៧០២ហិចតា ក្នុងឆ្នាំ២០១៥។ តារាងទី២ ក៏បង្ហាញផងដែរថាផ្ទៃដីសម្រាប់ការដាំស្រូវក៏កើនឡើងយ៉ាងឆាប់រហ័ស គឺបាន ១៥០,៨២៣ ហិចតា ថែមទៀត ហើយផ្ទៃដីសម្រាប់ការដាំស្រូវសរុបគ្របដណ្តប់ប្រហែល ៧៣% នៃផ្ទៃដីដាំដុះនៅក្នុងខេត្តបាត់ដំបង។ អាស្រ័យហេតុនេះ ផលិតកម្មស្រូវគឺជាប្រភពដ៏សំខាន់នៃការចិញ្ចឹមជីវិតសម្រាប់ប្រជាជនក្នុងខេត្តបាត់ដំបង បើយោងតាមទំហំផ្ទៃដីដាំដុះនៅក្នុងឆ្នាំ ២០១៥។

យោងផលិងផលសរុបនៃដំណាំ១៩ប្រភេទនៅបាត់ដំបង ដំឡូងមីមានចំណែកផលិផលធំជាងគេ (៦៩,៦៨%) បន្ទាប់មក គឺផលិតកម្មស្រូវ (២៣,៨៨%) និងពោត (៣,៩៤ %)។ ប្រសិនបើមានទីផ្សារ និងចង្វាក់ឧស្សាហកម្មកែច្នៃរឹងមាំនៅកម្ពុជានោះ ដំណាំដំឡូងមី និងពោត ទំនងជាផ្តល់ឱកាសការងារច្រើនដល់ប្រជាជន និងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនៅបាត់ដំបងជាពិសេស។[3] ដោយមានកម្លាំងពលកម្ម និងផ្ទៃដីដែលបានលកាប់ឆ្ការរួចហើយសំរាប់បង្កបង្កើនផល[4] ខេត្តនេះមានសក្តានុពលខ្ពស់សម្រាប់ទាក់ទាញការវិនិយោគដើម្បីបង្កើនផលិតកម្ម និងផលិតភាពកសិកម្ម សម្រាប់បង្កើតការងារ ព្រមទាំងកែលម្អជីវភាពរបស់ប្រជាជន។

តារាង២៖ ដំណាំដំឡូងមីជាចំណែកធំបំផុត នៃផលិតផលដំណាំសរុបនៅក្នុងខេត្ត

ធៀបនឹងផលសរុបជាតិ

| ដំណាំ | ផ្ទៃដីដាំដុះ (ហិចតា) | | | ផលិតផល (តោន) | % នៃ ផលិតផលសរុប | ផលិតផលទូទាំងប្រទេស | % នៃ ផលិតផលក្នុងខេត្តបាត់ដំបង |
|---|---|---|---|---|---|---|---|
| | 2015 | 2010/11 | ការផ្លាស់ប្តូរ 2015-2010/11 | | | | |
| ស្រូវ | 440,574 | 289,751 | 150,823 | 713,747 | 23.88% | 6,430,021 | 11% |
| ដំឡូងមី | 94,856 | 17,555 | 77,301 | 2,082,790 | 69.68% | 6,669,001 | 31% |
| ពោត | 37,373 | 66,603 | -29,230 | 117,921 | 3.94% | 273,231 | 43% |
| សណ្តែកសៀង | 11,637 | 25,057 | -13,420 | 22,650 | 0.76% | 103,017 | 22% |
| សណ្តែកបាយ | 7,106 | 11,053 | -3,947 | 9,481 | 0.32% | 53,024 | 18% |
| ល្ង | 4,943 | 8,959 | -4,016 | 4,532 | 0.15% | 18,585 | 24% |
| ស្វាយ | 2,577 | 890 | 1,687 | 11,633 | 0.39% | 2,536,498 | 0% |
| កៅស៊ូ | 2,520 | 406 | 2,114 | 1,178 | 0.04% | 1,137,865 | 0% |
| មៀន | 2432 | 928 | 1,504 | 18,292 | 0.61% | 26,418 | 69% |
| គ្រាប់ស្វាយចន្ទី | 889 | 126 | 763 | 1,120 | 0.04% | 1,121,013 | 0% |
| ក្រូច | 565 | 634 | -69 | 2,475 | 0.08% | 5,530 | 45% |
| សណ្តែកដី | 551 | 1,904 | -1,353 | 825 | 0.03% | 25,027 | 3% |

| ដំណាំ | ផ្ទៃដីដាំដុះ (ហិចតា) | | | ផលិតផល (តោន) | % នៃ ផលិតផលសរុប | ផលិតផលទូទាំងប្រទេស | % នៃ ផលិតផលក្នុងខេត្តបាត់ដំបង |
|---|---|---|---|---|---|---|---|
| | 2015 | 2010/11 | ការផ្លាស់ប្តូរ 2015-2010/11 | | | | |
| ដំឡូងជ្វា | 170 | 107 | 63 | 619 | 0.02% | 24,803 | 2% |
| អំពៅ | 161 | 269 | -108 | 1553 | 0.05% | 1,014,419 | 0% |
| ផ្លែស្រការនាគ | 129 | 91 | 38 | 298 | 0.01% | 460 | 65% |
| ម្រេចខ្មៅ | 129 | 4 | 125 | 31 | 0.00% | 314,236 | 0% |
| ធុរេន | 59 | 50 | 9 | 104 | 0.00% | 15,735 | 1% |
| មង្ឃុត | 21 | 20 | 1 | 29 | 0.00% | 479 | 6% |
| សាវម៉ាវ | 10 | 55 | -45 | 16 | 0.00% | 4,264 | 0% |
| ផលិតផលដំណាំទាំងអស់ | 606,702 | 424,459 | 182,243 | 2,989,292 | 100.00% | 19,773,626 | |

ប្រភព៖ ទិន្នន័យឃុំ ២០១០/១១-២០១៥ ក្រសួងផែនការ

ជាឧទាហរណ៍ កសិករបានប្រើប្រាស់ផ្ទៃដីថ្មីសម្រាប់ដាំដំណាំស្វាយ(១,៣៨៩ ហិចតា) កៅស៊ូ (២,៣៦០ ហិចតា) មៀន (៨៦២ ហិចតា) ស្វាយចន្ទី(២៨២ ហិចតា) ក្រូចពោធិសាត់ (១៨៩ ហិចតា) ម្រេចខ្មៅ (៩២ ហិចតា) ផ្លែស្រការនាគ( ៣៩ ហិចតា) ធុរេន(៣៥ ហិចតា) និងមង្ឃុត (១៤ ហិចតា) (តារាងទី២ និង ឧបសម្ព័ន្ធ៣)។ ទោះជាយ៉ាងណាក៏ដោយ ខណៈពេលរងចាំដំណាំទាំងនេះលូតលាស់ដល់ពេលប្រមូលផល ប្រសិនជាមានការវិនិយោគបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ និងកំណើនមត្រូវការបរិភោគក្នុងស្រុក នឹងនាំមកនូវការប្រើប្រាស់ដីកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតសំរាប់បង្កើនផលិតសិកម្មកសិផលផ្សេងទៀត។[5]

## ២.៣. កត្តាអំណោយផលសម្រាប់ទាក់ទាញការវិនិយោគ

ការវិនិយោគសកម្មភាពកសិកម្ម និងសេដ្ឋកិច្ចមូលដ្ឋានផ្សេងទៀតបានសម្របសម្រួលដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីៗនេះ រួមមាន ការកែលម្អប្រព័ន្ធផ្លូវជាតិ និងផ្លូវលំជនបទនៅតាមមូលដ្ឋាន និងអំណោយផលនៃទីតាំង ភាពសមប្បូរបែបនៃធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍសេវាកម្ម និងទីតាំងទេសចរណ៍វប្បធម៌ និងអេកូ-ទេសចរណ៍។ សក្តានុពលសម្រាប់ទាក់ទាញវិនិយោគដែលខេត្តបាត់តំបងរួមមានគឺ[6]៖

១. ទីតាំងភូមិសាស្ត្ររបស់ខេត្ត និងទំនាក់ទំនងជាមួយនឹងប្រទេសថៃសម្រាប់ការធ្វើពាណិជ្ជកម្មដែលសម្រួលដោយផ្លូវជាតិលេខ ៥ ដែលមានការកែលម្អ និងផ្លូវជាតិលេខ៥៧ ទៅកាន់ព្រំដែនប្រទេសថៃ រួមមានច្រកព្រំដែនអន្តរជាតិ ១កន្លែង និងច្រកព្រំដែនតាមតំបន់ចំនួន ៤ កន្លែង សម្រាប់សម្រួលដល់ការធ្វើពាណិជកម្ម។

២. មានបណ្ដាញដឹកជញ្ជូនល្អ តាមរយៈផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក ដែលតភ្ជាប់ទៅនឹងប្រទេសថៃ រាជធានីភ្នំពេញ និងបណ្ដាខេត្តនានា

៣. ដីមានជីជាតិសម្រាប់ដំណាំផ្សេងៗ និងប្រពន្ធ័ធារាសាស្ត្រដែលមានការអភិវឌ្ឍល្អ និងទំនប់ធំៗបី និង

៤. កម្លាំងពលកម្មដែលមានស្រាប់ និងកំពុងតែកើនឡើង

កត្តាអំណោយផលទាំងនេះ ប្រសិនបើមានផែនការអភិវឌ្ឍន៍ឲ្យបានត្រឹមនោះ នឹងផ្ដល់នូវបរិស្ថានអំណោយផលសម្រាប់ទាក់ទាញការវិនិយោគបន្ថែមទៀតចំពោះផលិតកម្មៈ

១. កសិកម្ម (ស្រូវ ដំឡូងមី ពោត សណ្ដែក និងបន្លែចម្រុះ) ការចិញ្ចឹមសត្វ (ក្របី ត្រី និងក្រពើ) ។ល។

២. ឧស្សាហកម្ម (រោងម៉ាស៊ីនស្រូវ ការកែច្នៃចំណីអាហារ និងទាញយករ៉ែ ជាដើម) និង

៣. ទេសចរណ៍ (លំហូរនៃចំនួនភ្ញៀវទេសចរណ៍ទៅកាន់ខេត្តបាត់ដំបងបានកើនឡើង)

## *២.៤. កត្តាប្រឈមដែលផលិតករក្នុងស្រុកជួបប្រទះ*

មិនមានការសិក្សាច្បាស់លាស់ណា ស្ដីពីបញ្ហាប្រឈមដែលផលិតករនៅក្នុងខេត្តបាត់ដំបងជួបប្រទះ សម្រាប់ជាឯកសារយោងនៃការស្រាវជ្រាវនេះទេ។ ភស្តុតាងដែលអាចដកស្រង់ចេញពីការសិក្សាថ្នាក់ជាតិដែលមានពិភាក្សានៅក្នុងអត្ថបទស្រាវជ្រាវក្នុងស្រុក និងអន្តរជាតិថ្មីៗនេះ ស្ដីពីការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចកម្ពុជា ពាក់ព័ន្ធនឹងកសិករ ឬផលិតករនៅខេត្តបាត់តំបង ត្រូវបានសង្ខេបដូចជាខាងក្រោមៈ

### ក. សម្រាប់ផលិតករ [7]

១. កង្វះសេវាផ្សព្វផ្សាយដែលមានប្រសិទ្ធិភាព សម្រាប់គាំទ្រដល់កសិករដែលចាប់យកគំនិតថ្មីៗនៃការធ្វើកសិកម្ម មកអនុវត្ត។

២. កង្វះយន្តការសហការណ៍ទ្វេរភាគី និងពត៌មានទីផ្សារ ដែលនាំឲ្យមានហានិភ័យខ្ពស់ដល់ការដាំដំណាំមួយចំនួន ពីព្រោះកសិករអាចរកទីផ្សារមិនបានសម្រាប់ផលិតផលរបស់ពួកគេ។

៣. ដោយមិនមានប្រាក់សន្សំគ្រប់គ្រាន់ កសិករអាចលក់ដីកសិកម្ម ហើយក្លាយជាពលករពនេចរ (mobile workers) និង ឬក៏បង្ខំលក់ផលិតផលកសិកម្មក្នុងតម្លៃទាបនៅពេលប្រមូលផលដើម្បីសងប្រាក់កម្ចីដែលពួកគេខ្ចីពីអ្នកចងការឯកជន ឬពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

៤.ការអភិវឌ្ឍឧស្សាហកម្មកែច្នៃ មានដំណើរការយឺតយ៉ាវ ក្នុងការកែលម្អចង្វាក់ផលិតកម្ម សំដៅបង្កើតតម្លៃបន្ថែមលើផលិតផលកសិកម្ម និងការបង្កើតការងារបន្ថែមទៀត។

៥. ការឡើងចុះនៃតម្លៃកសិផលដែលបានប៉ះពាល់ដល់ជីវភាព ហើយកសិករដែលតែងតែសុំបទអន្តរាគមន៍សមស្របពីរដ្ឋាភិបាលដើម្បីរក្សាស្ថេរភាពតម្លៃកសិកផល ត្រូវបានលើកយកមកផ្សាយជាញឹកញាប់តាមប្រពន្ធ័ផ្សព្វផ្សាយនានា។[8]

### ខ. ទីផ្សារ និងពាណិជ្ជកម្ម

១. ទោះបីជាមានការកើនឡើង នៃចំនួនក្រុមហ៊ុនអាហារ័ណ នីហារ័ណ ដែលនាំចេញអង្ក និងផលដំណាំផ្សេងៗក៏ដោយ ក៏ការនាំចេញកសិផលភាគច្រើនមានការពឹងផ្អែកលើទំនាក់ទំនងទីផ្សារជាមួយប្រទេសជិតខាង (ឧ. ប្រទេសថៃ និងវៀតណាម)[9][10][11]

២. ខណៈដែលស្ថានភាពផ្លូវ និងការថែទាំផ្លូវមានភាពប្រសើរឡើង[12] តម្លៃដឹកជញ្ជូនទំនិញ និងផលកសិកម្មនៅកម្ពុជានៅតែមានកម្រិតខ្ពស់ ប្រសិនបើធៀបទៅនឹងប្រទេសជិតខាងទាំងនោះ។[13]

៣. ការលើកកម្ពស់សេវាច្រកចេញចូលតែមួយ (one window services) សម្រាប់ការបង្កើត និងចុះបញ្ជីអាជីវកម្ម អាចជួយកាត់បន្ថយការចំណាយអាជីវកម្ម[14] ដែលចាំបាច់ត្រូវពង្រីកឲ្យបានទូទាំងប្រទេសដើម្បីបង្កើនគុណភាពផ្តល់សេវាសាធារណៈ និងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ។

### *២.៥. គោលនយោបាយឆ្លើយតបនៅក្នុងបរិបទនៃដំណើរការអភិវឌ្ឍន៍ និងវិមជ្ឈការ*

គោលនយោបាយផ្សេងៗគ្នាដោយរាជរដ្ឋាភិបាលកម្ពុជា ដូចជាការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា[15] គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម២០១៥-២០២៥[16] យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៣-២០១៨[17] និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០[18] ជួយធ្វើឲ្យប្រសើរឡើងនូវបណ្តា ហេដ្ឋារចនាសម្ព័ន្ធ ហើយនឹងជួយទាក់ទាញការវិនិយោគនៅក្នុងវិស័យសេដ្ឋកិច្ចដ៏ទៃទៀតក្រៅពីការដឹកជញ្ជូន ដើម្បីពង្រីកកំណើនសេដ្ឋកិច្ច[19]។ តារាងទី៣ សង្ខេបអំពីយុទ្ធសាស្ត្រគោលនយោបាយតម្រង់ទិស និងទំនាក់ទំនងទៅនឹងតួនាទី ភារកិច្ចនៃតួ អង្គសំខាន់នីមួយៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ។

តារាង ៣៖ គោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាលសម្រាប់ការគាំទ្រការអភិវឌ្ឍ និងការលើកឡើងអំពីបញ្ហាទីផ្សារនៃផលិតផលកសិកម្មនៅក្នុងខេត្តបាត់ដំបង

| | |
|---|---|
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ | ១) ការលើកកម្ពស់ការធ្វើពាណិជ្ជកម្ម ២) ពង្រឹងការរៀបចំស្ថាប័នដើម្បីលើកកម្ពស់ពាណិជ្ជកម្ម និងការនាំចេញផលិតផលកសិកម្ម ៣) លើកកម្ពស់សមត្ថភាពកែច្នៃ ៤) ការអនុវត្ត "សេវាច្រកចេញចូលតែមួយ" សម្រាប់កែលម្អបន្ថែមទៀតលើការសម្របសម្រួលពាណិជ្ជកម្ម ៥) ពង្រឹងប្រពន្ធ័ដឹកជញ្ជូន និងលើកកម្ពស់គុណភាពផលិតផលកសិកម្មឲ្យស្របទៅតាមស្តង់ដារអន្តរជាតិ ៦) បង្កើនសមត្ថភាពដើម្បីផ្តល់នូវឥណទានដែលមានតម្លៃសមរម្យ និង ៧) បង្កើនភាពជាដៃគូររវាងកសិករ និងពាណិជ្ជករ និងរវាងកសិ-ឧស្សាហកម្ម ខ្នាតតូច មធ្យម និងធំ |
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម<br>២០១៤-២០១៨ | ១) ពង្រឹងព័ត៌មានកសិកម្ម និងប្រពន្ធ័ទីផ្សារ<br>២)ការលើកកម្ពស់ការចូលទៅកាន់ទីផ្សារនៃផលិតផលកសិកម្ម តាមរយៈការកើនឡើងសមត្ថភាពបច្ចេកទេសនៃកសិ-ឧស្សាហកម្ម ការទំនាក់ទំនងទីផ្សារ និងលើកកម្ពស់គុណភាព និងសមត្ថភាពនៃផលិតផលកសិកម្មដោយគិតពីផលប៉ះពាល់លើសុខភាពសាធារណៈនិងបរិស្ថាន<br>៣) ការលើកកម្ពស់ការកែច្នៃផលិតផលកសិកម្ម និងការវិនិយោគនៅក្នុងកសិ-ឧស្សាហកម្ម ព្រមទាំងការពង្រឹងប្រព័ន្ធទីផ្សារកសិកម្ម និងឱកាសពង្រីកទីផ្សារ<br>៤) ការបង្កើត និងការចុះឈ្មោះរបស់សហករណ៍កសិកម្មបន្ថែមទៀត ដើម្បីផ្តល់សិទ្ធិអំណាច សមត្ថភាពចរចារ ភាពងាយស្រួលក្នុងការប្រើប្រាស់សេវាបច្ចេកទេស និងសេវាឥណទាន ហើយនឹងប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធាន។ |
| គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅក្នុងប្រទេសកម្ពុជា ២០១៥ | លើកទឹកចិត្តវិស័យឯកជន ដើម្បីបង្កើត និងដំណើរការមជ្ឈមណ្ឌលព័ត៌មានដោយផ្តោតលើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) នៅតាមជនបទ និងការប្រើប្រាស់ទូរសព្ទ័ទំនើបក្នុងការចែករំលែកព័ត៌មានទីផ្សារ និងបង្កើតកម្មវិធីវិទ្យុ និងទូរទស្សន៍ដោយផ្តោតលើកសិដ្ឋាននៅតាមសហគមន៍។ |
| គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ | ១) លើកកម្ពស់យ៉ាងសកម្មនូវការវិនិយោគផ្ទាល់ពីបរទេស(FDI)ដែលផ្តោតលើការរីកចម្រើនបរិយាកាសវិនិយោគ ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស(SEZs) និងការរៀបចំតំបន់ឧស្សាហកម្ម<br>២) ពង្រឹង និងធ្វើទំនើបកម្មសហគ្រាសធនតូច និងមធ្យម(SMEs) ដោយផ្តោតលើការបង្កើត និងផ្តល់រង្វាន់ទឹកចិត្តរបស់ពួកគេ( focusing on their formalization and the provision of incentives) រួមមាន ការជំរុញឲ្យធ្វើបញ្ជីកត់ត្រា និង គណនេយ្យត្រឹមត្រូវ ព្រមទាំងលើកកម្ពស់វិស័យកសិ-ឧស្សាហកម្ម<br>៣) ការធ្វើឲ្យប្រសើរឡើងនូវបទប្បញ្ញត្តិបរិស្ថានដោយផ្តោតលើវិធានការសម្រប |

| | |
|---|---|
| | សម្រួលពាណិជ្ជកម្ម និងការលើកកម្ពស់ការនាំចេញ ការពង្រឹងស្តង់ដារឧស្សាហកម្ម និងកម្មសិទ្ធិបញ្ញាក្នុងវិស័យឧស្សាហកម្ម (industrial property rights) ការសម្របសម្រួលកាតព្វកិច្ចបង់ពន្ធ ការបង្កើតទីផ្សារការងារ និងការធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងឧស្សាហកម្ម ៤) ការសម្របសម្រួលគោលនយោបាយគាំទ្រដោយផ្តោតលើការអភិវឌ្ឍជំនាញ និងធនធានមនុស្ស វិទ្យាសាស្ត្រ ការលើកកម្ពស់បច្ចេកវិទ្យា និងការច្នៃប្រឌិត ការកសាងហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងវិធានហិរញ្ញប្បទាន។ |
| គោលនយោបាយអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ | ១) ការការពារតំបន់បេតិកភណ្ឌវប្បធម៌ និងលើកកម្ពស់ការអភិវឌ្ឍអេកូទេសចរណ៍ គឺត្រូវបានចាត់ទុកជាវិស័យអភិវឌ្ឍន៍អាទិភាព<br>២) ការអភិវឌ្ឍធនធានមនុស្ស និងការពង្រីកទីកន្លែងទេសចរណ៍ និងការបំពាក់បំប៉នភាសាបរទេសសម្រាប់មគ្គុទេសទេសចរណ៍ដែលមានជំនាញ<br>៣) សុវត្ថិភាព និងការគ្រប់គ្រងផលប៉ះពាល់ផ្នែកទេសចរណ៍ តម្រូវឲ្យមានការគាំទ្រប្រកបដោយប្រសិទ្ធិភាពសម្រាប់ការអនុវត្តដ៏ជោគជ័យនៃគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព<br>៤) ទំនាក់ទំនងសេដ្ឋកិច្ច និងសុវត្ថិភាពចំណីអាហារ គឺជាបញ្ហាចម្បងដែលត្រូវលើកឡើង ដើម្បីលើកកម្ពស់សេវាទេសចរណ៍ក្នុងចំណោមវិធានការយុទ្ធសាស្ត្រដ៏ទៃទៀត។ |

ដើម្បីបង្កើនគុណប្រយោជន៍សេដ្ឋកិច្ច សម្រាប់កំណើនសេដ្ឋកិច្ចជាតិ និងសម្រាប់ខេត្តបាត់ដំបង វាត្រូវការចាំបាច់នូវផែនការអភិវឌ្ឍន៍ខេត្ត ដែលមានការសម្របសម្រួល ការពង្រឹងធនធានមនុស្ស ហើយនឹងធ្វើឲ្យកាន់តែប្រសើរឡើងនូវការដឹកជញ្ជូន និងនីតិវិធីគយ ជាមួយនឹងប្រទេសអាស៊ានដ៏ទៃទៀត។[20] លើសពីនេះទៅទៀត កិច្ចព្រមព្រៀងស្តីពីក្របខ័ណ្ឌរួមនៃការសម្របសម្រួលការចរាចរណ៍ដោយសេរីរបស់ប្រជាពលរដ្ឋ ទំនិញ និងការធ្វើពាណិជ្ជកម្មនៅក្នុងតំបន់ចំបាច់ត្រូវផ្តល់សច្ចាប័ន សម្រាប់ការធ្វើសមាហរណកម្មប្រកបដោយអត្ថន័យ នៃសេដ្ឋកិច្ចកម្ពុជាទៅក្នុងអាស៊ាន។[21]

ការធ្វើឲ្យល្អប្រសើរឡើងនូវបណ្តាញដឹកជញ្ជូន នឹងនាំឲ្យមានការកាត់បន្ថយការចំណាយលើការដឹកជញ្ជូន និងមានភាពប្រសើរឡើងនូវការប្រកួតប្រជែងក្នុងការនាំចេញ ប្រសិនបើឧបសគ្គស្ថាប័នមួយចំនួនដូចជា ការចំណាយខ្ពស់លើការបង្កើតអាជីវកម្ម និងនីតិវិធីគយមិនច្បាស់លាស់ត្រូវបានដោះស្រាយ។ កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដោយរាជរដ្ឋាភិបាលនាប៉ុន្មានឆ្នាំកន្លងមក អាចធ្វើឲ្យប្រទេសកម្ពុជាទទួលបានលេខរៀងទី ២៩ ក្នុងចំណាត់ថ្នាក់នៃការដឹកជញ្ជូន (Logistics Performance Ranking) របស់ធនាគារពិភពលោក។[22]

ឧទាហរណ៍ចំនួនពីរនៃសមទ្ធិផលដ៏ល្អដែលសម្រេចបាន ដែលអាចមើលឃើញតាមរយៈសមាគមកសិករចំនួនពីរដែលបានអភិវឌ្ឍន៍អាជីវកម្មរបស់ខ្លួនយ៉ាងប្រសើរ គឺសមាគមម្រេចកំពត និងសមាគម

មៀនប៉ៃលិន។ សមាគមទាំងពីរនោះត្រូវបានផ្តួចផ្តើម និងគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការយ៉ាងជិតស្និតជាមួយនឹងអាជ្ញាធរមូលដ្ឋាន។ ពួកគេបានទទួលនូវភាពជោគជ័យក្នុងការសម្រេចនូវគោលបំណងចម្បងរបស់ពួកគេ៖ ១) ពង្រឹងគុណប្រយោជន៍សេដ្ឋកិច្ចរបស់កសិករ ពីកំណើនសេដ្ឋកិច្ច ២) ការពង្រឹងការធ្វើទីផ្សារ តាមរយៈការប្រមូលទិញ និងលក់ ៣) ការពង្រឹងទំនាក់ទំនង និងកិច្ចសហការរវាងកសិករក្នុងមូលដ្ឋាន អាជីវកម្ម និងអ្នកវិនិយោគ និង៤) សម្រួលដល់ការទទួលយក និងចែករំលែកចំណេះដឹងពាក់ពន្ធ័នឹងកសិកម្មទៅដល់កសិករ។[23] ឥឡូវសមាគមនេះ គឺអាចបង្កើតទំនាក់ទំនងទីផ្សារជាតិ និងអន្តរជាតិ និងបណ្តាញទីផ្សារសម្រាប់ផលិតផលរបស់ពួកគេ។ ជាមួយនឹងការគាំទ្រពីរាជរដ្ឋាភិបាល ម្រេចកំពត និងមៀនប៉ៃលីន ត្រូវបានចុះបញ្ជីជាមួយសញ្ញាពាណិជ្ជកម្មកម្ពុជា។ ទាំងរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសទៅដល់កសិករតាមរយៈសមាជិកភាពរបស់ពួកគេនៅក្នុងសមាគម។ ជាការកត់សម្គាល់ផងដែរថា ការធ្វើផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិដែលទទួលបានជោគជ័យដែលពាក់ព័ន្ធសមាគមទាំងពីរនេះ គឺពឹងផ្អែកយ៉ាងខ្លាំងលើការពង្រីកនៃសមាជិកភាពនៅទូទាំងដែនកំណត់រដ្ឋបាលឃុំ និង/ឬស្រុក ដើម្បីបង្កើនអំណាចចរចារ និងដើម្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាដើម្បីធានានូវបរិមាណ និងគុណភាពនៃផលិតផលរបស់ពួកគេសម្រាប់បំពេញនូវតម្រូវការទីផ្សារអន្តរជាតិ។

## *២.៦.ការពង្រឹងតួនាទីនៃរដ្ឋាភិបាលថ្នាក់ក្រោមជាតិ*

ទាក់ទងទៅនឹងការពង្រឹងតួនាទីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ វាជាការសំខាន់ណាស់ក្នុងការស្វែងយល់ពី រចនាសម្ព័ន្ធ និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិនេះ ដោយផ្អែកលើច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០០៨[24] និង គោលនយោបាយភូមិឃុំមានសុវត្ថិភាព។[25] រដ្ឋបាលថ្នាក់ក្រោមជាតិមានបីថ្នាក់៖១)រដ្ឋបាលថ្នាក់ខេត្ត ២)រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និង ៣)រដ្ឋបាលឃុំ សង្កាត់។ រដ្ឋបាលថ្នាក់ក្រោមជាតីទាំងបីថ្នាក់មានគណៈកម្មាធិការអភិវឌ្ឍមួយចំនួន (រូបភាពទី១)។

តួរអង្គសំខាន់ទាំងបីនេះ ត្រូវបានរំពឹងថានឹងអនុវត្តការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់សេវាកម្ម ដោយពង្រឹង នឹងអនុវត្ត ការធ្វើផែនការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋានរបស់ ឃុំ សង្កាត់ និងការធ្វើផែនការវិនិយោគសម្រាប់សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ដើម្បីប្រមូលនិធិពីរដ្ឋាភិបាល និង/ឬពីក្រសួងមហាផ្ទៃ។[26]

តួនាទីសំខាន់មួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពដែលធានានូវសណ្តាប់ធ្នាប់សង្គម និងសុវត្ថិភាពសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅមូលដ្ឋាន។ ភាពជោគជ័យនៃគោលនយោបាយនេះ គឺពឹងផ្អែកលើសហប្រតិបត្តិការល្អរវាងប៉ូលីស និងក្រុមប្រឹក្សា។[27] តួនាទីសំខាន់ផ្សេងទៀតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគឺ លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចេរភាព នៅក្នុងដែនដីរដ្ឋបាលរបស់ពួកគេ (រូបភាពទី១)។ លើសពីនេះទៅទៀត

ផែនការអភិវឌ្ឍថ្នាក់ក្រោមជាតិ គួរយកចិត្តទុកដាក់លើថាមពលដែលបានបង្កើតដោយការប្រែប្រួលសេដ្ឋកិច្ច និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ ពុំទាន់មានការយកចិត្តទិកដាក់បែបនេះនៅក្នុងផែនការអភិវឌ្ឍឃុំ (CDP) និងផែនការវិនិយោគឃុំ (CIP) បច្ចុប្បន្ន ហើយសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត។[28]

ការពង្រឹងតួនាទី និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយចេរភាព នៅក្នុងដែនសមត្ថកិច្ចរបស់ពួកគេ គឺពឹងផ្អែកលើកម្រិតធនធានរបស់រដ្ឋបាលថ្នាក់មូលដ្ឋាន។ គោលបំណង គឺដើម្បីគាំទ្រនូវសមត្ថភាពឃុំសង្កាត់ដើម្បីរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ ឃុំ និងផែនការវិនិយោគឃុំរបស់ពួកគេ ដែលនឹងត្រូវបានរួមបញ្ចូលគ្នា ទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ខេត្តរយៈពេលវែង សម្រាប់គាំទ្រ ការសម្របសម្រួលពីរដ្ឋាភិបាលថ្នាក់កំពូល វិស័យឯកជន ដៃគូអភិវឌ្ឍន៍នានា និងអង្គការក្រៅរដ្ឋាភិបាល (NGOs) (រូបភាពទី១)។

រូបទី 1: កិច្ចសហការណ៍ ដើម្បីលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននិង ទីផ្សារក្នុងបរិវេណ
វិមជ្ឈការនិងវិសហមជ្ឈការ




បញ្ហាប្រឈមនាពេលបច្ចុប្បន្នដែលបានជួបប្រទះនៅក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ គឺមានទំនាក់ទំនងគ្នាជាមួយនឹងស្វ័យភាពសារពើពន្ធនៅ ពេលដែលរដ្ឋបាលថ្នាក់ឃុំ សង្កាត់ និងស្រុក មិនមានសមត្ថភាពលែលកបង្កើតប្រាក់ចំណូល ឬក៏សិទ្ធិអំណាច និងភាពបត់បែននៅក្នុងការប្រើធនធានក្នុងមូលដ្ឋានដែលមានស្រាប់សម្រាប់ការអនុវត្តផែនកាអភិវឌ្ឍន៍ណាដែលជាអាទិភាព។[29]

## ៣. ជម្រើសគោលនយោបាយ

ខេត្តបាត់ដំបង គឺស្ថិតនៅក្នុងដំណាក់កាលនៃការផ្លាស់ប្តូរ និងពិពិធកម្មនៅក្នុងវិស័យកសិកម្ម។ ដោយសារតែទីតាំងភូមិសាស្ត្រ និងការតភ្ជាប់ការដឹកជញ្ជូនរបស់ខេត្តមានលក្ខណៈល្អប្រសើរ ធ្វើឲ្យខេត្តមានទំនាក់ទំនងសេដ្ឋកិច្ចយ៉ាងរឹងមាំជាមួយប្រទេសថៃសម្រាប់ការធ្វើពាណិជ្ជកម្មឆ្លងដែន។ ផលិតផលភាគច្រើនរបស់ខេត្តបានទៅដល់ទីផ្សារអន្តរជាតិ តាមរយៈប្រទេសថៃសម្រាប់ការវេចខ្ចប់ម្តងទៀត និងការកែច្នៃ។ ដោយសារតែសមត្ថភាពនៃការទំនាក់ទំនងទីផ្សារជាមួយអ្នកទិញអន្តរជាតិនានានៅមានកម្រិត មិនដូចផលិតផលរបស់កសិករដែលជាសមាជិកសមាគមម្រេចកំពត និងមៀនប៉ៃលិន អ្នកដាំដំណាំស្រូវនឹងដំណាំចំការនៅក្នុងខេត្តបាត់ដំបងជាញឹកញាប់តែងតែប្រឈមនូវហានិភ័យខ្ពស់ក្នុងការស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់ពួកគេ។ ដូចគ្នានេះដែរប្រជាជននៅក្នុងខេត្តបាត់ដំបង និងអាជ្ញាធរមូលដ្ឋានហាក់ដូចជាមិនទាន់សម្រេចបានផលប្រយោជន៍យ៉ាងពេញលេញនៃការអភិវឌ្ឍវប្បធម៌ និងអេកូទេសចរណ៍ព្រមទាំងការធ្វើសមាហរណកម្មការអភិវឌ្ឍនេះទៅក្នុងផែនការថ្នាក់ក្រោមជាតិ។[30]

រូបភាពទី១ បង្ហាញពីតម្រូវការសម្រាប់ការធ្វើឲ្យប្រសើរឡើងនូវការសហការរវាងក្រសួងពាក់ព័ន្ធ និងគាំទ្រសម្រាប់ការជួយដោះស្រាយបញ្ហាដែលកសិករបានជួបប្រទះ នៅក្នុងការស្វែងរកទីផ្សារសម្រាប់ដំណាំចំការរបស់ពួកគេនាពេលបច្ចុប្បន្ន នៅក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ។ ទីមួយ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ព្រមទាំងក្រសួងពាណិជ្ជកម្ម និងក្រសួងទេសចរណ៍គួរមានផែនការរួមគ្នាក្នុងការគាំទ្រយ៉ាងពេញទំហឹងក្នុងការការកសាងសម្ថភាពមូលដ្ឋាន សម្រាប់ការការអភិវឌ្ឍវិស័យកសិកម្ម និងការអភិវឌ្ឍទីផ្សារនិងបណ្តាញកសិកម្ម។

ទីពីរ ការយកចិត្តទុកដាក់នៃការធ្វើអន្តរាគមន៍គោលនយោបាយគួតែផ្តោតសំខាន់លើការបង្កើត និងការកសាងសមត្ថភាពរបស់កសិករនានា និង/ឬសមាគមអាជីវកម្ម។ ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន និង/ឬ ក៏រដ្ឋាបាលថ្នាក់ក្រោមជាតិ សមាគមកសិករ និងសមាគមអាជីវកម្មអាចនឹងបង្កើតឡើងដោយសមាជិកណាដែលមានការចាប់អារម្មណ៍ និងមានបញ្ហាដូចគ្នាទាក់ទងនឹងផលិតផលដំណាំចំការ និងសកម្មភាពអាជីវកម្មដែលពួកគេគួរតែអនុវត្ត។ ប្រធានសមាគមដែលទើបតែបង្កើតថ្មីនេះគួរតែត្រូវបានជ្រើសរើសដោយសមាជិកដែលធ្វើកសិកម្មទាំងនោះ។ បន្ទាប់មកសមាគមអាចពង្រីកខ្លួន ដោយមានសមាជិកពី ឃុំ និង/ឬស្រុក/សង្កាត់ ផ្សេងៗ ប្រការនេះនឹងបង្កើនអំណាចចរចារតាមរយៈសកម្មភាពរួម។

ទីបី ភាពជោគជ័យនៃការខិតខំប្រឹងប្រែងរបស់សមាគមនេះ នឹងពឹងផ្អែកលើការគាំទ្រពីដំណើរការកសាងផែនការក្នុងមូលដ្ឋានដូចជា ផែនការអភិវឌ្ឍន៍ឃុំ(CDP) និង/ឬផែនការវិនិយោគឃុំ(CIP)។ ផែនការអភិវឌ្ឍន៍ និងការវិនិយោគឃុំ អាចកៀរគរការគាំទ្រពីនាយកដ្ឋានបច្ចេកទេសដែលពាក់ពន្ធ័

អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន សម្រាប់ការកសាងសមត្ថភាពរបស់សមាគមកសិករដែលបានបង្កើតថ្មីនេះ។ នៅក្នុងដំណើរការនេះ សមាគមនិមួយៗអាចរៀនពីភាពជោគជ័យរបស់សមាគមម្រេចកំពត និងមៀនប៉ៃលិន ដើម្បីបង្កើតផែនការយុទ្ធសាស្ត្រដាច់ដោយឡែករបស់ខ្លួន ក្នុងការលើកកម្ពស់សមាជិកភាព និងប្រតិបត្តិការអាជីវកម្ម ព្រមទាំងការវិនិយោគរបស់ខ្លួន។ បន្ទាប់មកផែនការរបស់ពួកគេអាចនឹងបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងការវិនិយោគឃុំ ដែលជាកម្រិតដែនសីមានៃការសម្របសម្រួលការធ្វើផែនការ សម្រាប់ជាការគាំទ្រដល់ផែនការអាជីវកម្ម និងសកម្មភាពនានានៃសមាគមនិមួយៗ នៅឯថ្នាក់ស្រុក និង/ឬខេត្ត។ ទីបួន ការបណ្តុះបណ្តាលភាពជាសហគ្រិន និងការធ្វើផែនការអាជីវកម្ម គឺចាំបាច់សម្រាប់ការកសាងសមត្ថភាពរបស់សមាគមនីមួយៗ ព្រមទាំងសមាជិករបស់ពួកគេ។

ទីប្រាំ ចំនុចសំខាន់មួយផ្សេងទៀតនៃការគាំទ្រសម្រាប់ទាំងក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាគម គឺជាការបង្កើត និងការប្រើប្រាស់ទូរសព្ទ័ទំនើប ឬក៏ប្រពន្ធ័ទំនាក់ទំនងឌីជីថល និង/ឬប្រពន្ធ័ផ្សព្វផ្សាយទ្រង់ទ្រាយធំ សម្រាប់ជាការផ្តល់ព័ត៌មានទីផ្សារថ្មីៗ និងអ្វីដែលជាតម្រូវការសម្រាប់ការជ្រើសរើសដំណាំចំការជាក់លាក់ណាមួយក្នុងការពង្រីកអាជីវកម្ម។ លើសពីនេះទៅទៀត ការចុះកិច្ចសន្យារវាងកសិករ និងសហគ្រិន ជាមួយនឹងការងើបឡើងរបស់កសិ-សហគ្រាស និងបណ្តាញអាជីវកម្មដ៏ទៃទៀត ក៏អាចជាដំណោះស្រាយផ្សេងទៀតសម្រាប់ការជួយដល់អ្នកដាំដំណាំចំការធន់មធ្យម និងធន់ធំ និងសមាគមទេសចរណ៍ដែលពាក់ពន្ធ័នៅក្នុងខេត្តនេះ។ ជម្រើសគោលនយោបាយទាំងនេះត្រូវការគាំទ្រយ៉ាងខ្លាំងពីរដ្ឋាភិបាល (ឧ. ការផ្តល់ការទំនុកបំរុងជាថវិកា ការការពារសម្រាប់សមាគមដែលបានបង្កើតថ្មី និងការអភិវឌ្ឍ ការចុះកិច្ចសន្យាកសិកម្មសម្រាប់ពេលវេលាជាក់លាក់ណាមួយ)។

ឧបសម្ព័ន្ធទី១៖ ផលិតផលស្រូវសរុបតាមខេត្ត ២០១៥

| | ស្រូវវស្សាសរុប (តោន) | ផលិតផលស្រូវប្រាំងសរុប | សរុប | % |
|---|---|---|---|---|
| ព្រៃវែង | 468,708 | 313,273 | 781,981 | 12.2% |
| តាកែវ | 48,897 | 369,818 | 718,715 | 11.2% |
| បាត់ដំបង | 650,004 | 6,743 | 713,747 | 11.1% |
| កំពង់ធំ | 342,273 | 145,678 | 487,951 | 8% |
| សៀមរាប | 359,999 | 46,876 | 406,874 | 6% |
| បន្ទាយមានជ័យ | 342,80 | 45,771 | 388,621 | 6% |
| កណ្តាល | 76,204 | 28,835 | 364,039 | 6% |
| កំពត | 312,811 | 8,635 | 351,445 | 5% |
| កំពង់ឆ្នាំង | 227,740 | 103,631 | 331,371 | 5% |
| កំពង់ចាម | 202,342 | 106,393 | 308,735 | 5% |
| ស្វាយរៀង | 235,636 | 46,540 | 282,76 | 4% |
| ពោធិ៍សាត់ | 204,947 | 4,361 | 239,308 | 4% |
| កំពង់ស្ពឺ | 227,422 | 2,297 | 229,720 | 4% |
| ត្បូងឃ្មុំ | 165,702 | 33,957 | 199,59 | 3% |
| ព្រះវិហារ | 161,622 | 279 | 161,90 | 3% |
| ឧត្តរមានជ័យ | 150,05 | 549 | 150,595 | 2% |
| ក្រចេះ | 60,568 | 34,045 | 94,614 | 1% |
| ស្ទឹងត្រែង | 53,388 | 191 | 53,579 | 1% |
| មណ្ឌលគិរី | 34,773 | - | 34,773 | 1% |
| ព្រះសីហនុ | 3,253 | 240 | 34,493 | 1% |
| រតនគិរី | 28,927 | 4 | 28,931 | 0% |
| ភ្នំពេញ | 22,472 | 2,316 | 24,787 | 0% |
| ប៉ៃលិន | 8,030 | 8,573 | 16,603 | 0% |
| កោះកុង | 16,103 | 4 | 16,107 | 0% |
| កែប | 9,258 | 38 | 9,296 | 0% |
| សរុប | 4,744975 | 1,685,046 | 6,430021 | 00% |

ប្រភព៖ ទិន្នន័យឃុំ ២០១៥ ក្រសួងផែនការ

ឧបសម្ព័ន្ធ២៖  សមាមាត្រនៃការប្រើប្រាស់ផ្ទៃដីតាមប្រភេទនៅក្នុងឆ្នាំ ២០១៦ សម្រាប់ការបង្កើតសន្ទស្សន៍នៃការគូរផែនទី

| ស្រុក | ផ្ទៃដីកសិកម្មសរុប | % នៃផ្ទៃដីស្រូវ | % នៃផ្ទៃដីចំការ | ផ្ទៃដីស្រូវ ធៀបនឹងចំការ |
|---|---|---|---|---|
| កម្រៀង | 41,597 | 27% | 72% | -44% |
| គាស់ក្រឡ | 56,619 | 80% | 10% | 69% |
| ថ្មគោល | 52,906 | 87% | 0% | 86% |
| បវេល | 64,176 | 83% | 17% | 66% |
| បាណន់ | 44,949 | 72% | 25% | 47% |
| បាត់ដំបង | **37,287** | **16%** | **9%** | **8%** |
| ភ្នំព្រឹក | 54,896 | 13% | 87% | -74% |
| មោងឫស្សី | 78,131 | 88% | 4% | 84% |
| រតនមណ្ឌល | 516,359 | 19% | 81% | -62% |
| រុក្ខាគីរី | 43,999 | 40% | 28% | 12% |
| សង្កែ | 40,267 | 93% | 4% | 88% |
| សំពៅលូន | 21,175 | 24% | 76% | -53% |
| សម្លូត | 43,197 | 10% | 75% | -65% |
| ឯកភ្នំ | 18,073 | 45% | 34% | 11% |
| **ស្រុកទាំងអស់** | 1,113,631 | 40% | 54% | -14% |

ប្រភព៖ ទិន្នន័យឃុំ ២០១៥ ក្រសួងផែនការ

**កំណត់ចំណាំ៖** ការបែងចែកត្រូវបានកំណត់ដោយអ្នកនិពន្ធ

១. ពឹងផ្អែកយ៉ាងខ្លាំងលើផលិតផលស្រូវ = >=- 40 % (ឧ.ទ 30 % ដីស្រែ -70 % ដីចំការ)

២. ពឹងផ្អែកគួរសមលើដីចំការ = <-20%-39%

៣. ពឹងផ្អែកលើទាំងដីចំការ និងដីស្រែ = - 18% - + 19 %

៤. ពឹងផ្អែកគួរសមលើដីស្រែ= + 20% - 39 %

5. ពឹងផ្អែកខ្លាំងលើផលិតផលស្រូវ = + 40 % (ឧ.ទ. 70 % ដីស្រែ  - 30% ដីចំការ)

ឧបសម្ព័ន្ធ៣៖ ផលិតផលដំណាំនៃខេត្តបាត់ដំបង ប្រៀបធៀបផលិតផលទូទាំងប្រទេសតាមប្រភេទដំណាំ ឆ្នាំ ២០១៥

| ល.រ | ប្រភេទដំណាំ | ខេត្តបាត់ដំបង | | | | គ្រប់ខេត្តទាំងអស់ | | |
|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីដាំដុះ (ហិចតា) | ទិន្នផល (តោន/ហិចតា) | ផលិតផល (តោន) | % នៃ ផលិតផលទូទាំងប្រទេស | ផ្ទៃដីដាំដុះ (ហិចតា) | ទិន្នផល (តោន/ហិចតា) | ផលិតផល (តោន) |
| 1 | ដំឡូងមី | 94,856 | 22.0 | 2,082,790 | 31% | 564,827 | 11.8 | 6,669,001 |
| 2 | ស្រូវ | 440,574 | 2.2 | 713,747 | 11% | 3,025,917 | 2.6 | 6,430,021 |
| 3 | ពោត | 37,373 | 3.2 | 117,921 | 43% | 83,271 | 3.3 | 273,231 |
| 4 | សណ្តែកសៀង | 11,637 | 1.9 | 22,650 | 22% | 56,280 | 1.8 | 103,017 |
| 5 | មៀន(ប្រមូលផល) | 1,570 | 11.7 | 18,292 | 69% | 3,029 | 8.7 | 26,418 |
| 6 | ស្វាយ (ប្រមូលផល) | 1,188 | 9.8 | 11,633 | 0% | 80,248 | 31.6 | 2,536,498 |
| 7 | សណ្តែកខៀវ | 7,106 | 1.3 | 9,481 | 18% | 34,845 | 1.5 | 53,024 |
| 8 | ល្ង | 4,943 | 0.9 | 4,532 | 24% | 16,665 | 1.1 | 18,585 |
| 9 | ក្រូចពោធិសាត់ (ប្រមូលផល) | 376 | 6.6 | 2,475 | 45% | 1,138 | 4.9 | 5,530 |
| 10 | អំពៅ | 161 | 9.6 | 1,553 | 0% | 69,608 | 14.6 | 1,014,419 |
| 11 | កៅស៊ូ (ប្រមូលផល) | 161 | 7.3 | 1,178 | 0% | 183,032 | 6.2 | 1,137,865 |
| 12 | គ្រាប់ស្វាយចន្ទី (ប្រមូលផល) | 607 | 1.8 | 1,120 | 0% | 140,653 | 8.0 | 1,121,013 |
| 13 | សណ្តែកដី | 551 | 1.5 | 825 | 3% | 13,516 | 1.9 | 25,027 |
| 14 | ដំឡូងជ្វា | 170 | 3.6 | 619 | 2% | 6,436 | 3.9 | 24,803 |
| 15 | ស្រការនាគ (ប្រមូលផល) | 90 | 3.3 | 298 | 65% | 184 | 2.5 | 460 |
| 16 | ធុរេន (ប្រមូលផល) | 24 | 4.3 | 104 | 1% | 3,208 | 4.9 | 15,735 |
| 17 | ម្រេចខ្មៅ (ប្រមូលផល) | 37 | 0.9 | 31 | 0% | 72,178 | 4.4 | 314,236 |
| 18 | មង្ឃុត (ប្រមូលផល) | 7 | 4.2 | 29 | 6% | 124 | 3.9 | 479 |
| 19 | សាវម៉ាវ (ប្រមូលផល) | 9 | 1.7 | 16 | 0% | 635 | 6.7 | 4,264 |
| | ផ្ទៃដីដាំដុះ(ហិចតា) | | | | | | | |
| | កៅស៊ូ(ដាំដុះ) | 2,520 | | - | | 514,984 | | - |
| | គ្រាប់ស្វាយចន្ទី(ដាំដុះ) | 889 | | - | | 218,019 | | - |
| | ម្រេចខ្មៅ (ដាំដុះ) | 129 | | - | | 121,065 | | - |
| | ស្វាយ(ដាំដុះ) | 2,577 | | - | | 115,423 | | - |
| | មៀន (ដាំដុះ) | 2,432 | | - | | 6,506 | | - |
| | ធូរេន (ដាំដុះ) | 59 | | - | | 3,745 | | - |
| | ក្រូច(ដាំដុះ) | 565 | | - | | 2,767 | | - |
| | សាវម៉ាវ (ដាំដុះ) | 10 | | - | | 796 | | - |
| | ស្រការនាគ(ដាំដុះ) | 129 | | - | | 290 | | - |
| | មង្ឃុត(ដាំដុះ) | 21 | | - | | 196 | | - |

ប្រភព៖ ទិន្នន័យឃុំ ឆ្នាំ ២០១៥ ក្រសួងផែនការ

# ឯកសារយោង

[1] ROYAL GOVERNMENT OF CAMBODIA 2013. National Strategic Development Plan 2014-2018. Phnom Penh: Ministry of Planning.p.8

[2] SOKUNKOLYAN, T., PAUL, C. & SU, Y. Z. K. 2016. Addressing Marketing Problems of Farmers in Ratanakiri Province. Phnom Penh: Parliamentary Institute of Cambodia.

[3] Ibid.

[4]WORLD BANK 2015. Cambodian Agriculture in Transition: Opportunities and Risks. [Accessed on 23 October 2015].

[5] CDC Battambang Province. Phnom Penh, Cambodia: Council for Development of Cambodia.

[6] Ibid.

[7] FITZGERALD, I., SUVAṆṆĀRIDDHI, S. & SUPHAL, C. 2007. *Moving Out of Poverty?: Trends in Community Well-being and Household Mobility in Nine Cambodian Villages*, CDRI.

[8] MUYHONG, C. 2014. Farmers air their agriculture concerns *Phnom Penh Post*

[9] SOKUNKOLYAN, T., PAUL, C. & SU, Y. Z. K. 2016. Addressing Marketing Problems of Farmers in Ratanakiri Province. Phnom Penh: Parliamentary Institute of Cambodia.

[10] WORLD BANK 2015. Cambodian Agriculture in Transition: Opportunities and Risks.

[11] VUTHA, H. & VATHANA, T. 2009. Agricultural Trade in the Greater Mekong Sub-region: The Case of Cassava and Rubber in Cambodia. 43.

[12] ASIAN DEVELOPMENT BANK 2011. Cambodia: Transport Sector Assessment, Strategy, and Road Map. Phillipine.

[13] ROYAL GOVERNMENT OF CAMBODIA 2014. Cambodia Trade Integration Strategy 2014-2018. Phnom Penh., and see also SEREYVATH, P. 2015. Pepper Value Chain Analysis : Actors, Activities and their Challenge *Current Status of Pepper Business in Cambodia and Ways Forward.* Phnom Penh, Cambodia: CIRD.

[14] SOKUNKOLYAN, T., PAUL, C. & SU, Y. Z. K. 2016. Addressing Marketing Problems of Farmers in Ratanakiri Province. Phnom Penh: Parliamentary Institute of Cambodia.

[15] WARR, P. & MENON, J. 2015. Cambodia's Special Economic Zones. *Economic* 459.

[16] ROYAL GOVERNMENT OF CAMBODIA 2015. Cambodia Industrial Development Policy 2015-2025. Phnom Penh: Royal Government of Cambodia.

[17] CTIS 2013 INTER-MINISTERIAL COMMITTEE(TASK FORCE) 2013. Cambodia Trade Integration Strategy 2013-2018 and Trade SWAp Road Map 2013-2018. Phnom Penh.

[18] ROYAL GOVERNMENT OF CAMBODIA 2012. TOURISM DEVELOPMENT STRATEGIC PLAN 2012-2020. Phnom Penh, Cambodia: Ministry of Tourism.

[19] WARR, P. & MENON, J. 2015. Cambodia's Special Economic Zones. *Economic* 459.

[20] Ibid.

[21] SOKUNKOLYAN, T., PAUL, C. & SU, Y. Z. K. 2016. Addressing Marketing Problems of Farmers in Ratanakiri Province. Phnom Penh: Parliamentary Institute of Cambodia.

[22] WORLD BANK 2016. Country Score Card: Cambodia 2016. World Bank.

[23] SOKUNKOLYAN, T., PAUL, C. & SU, Y. Z. K. 2016. Addressing Marketing Problems of Farmers in Ratanakiri Province. Phnom Penh: Parliamentary Institute of Cambodia.

[24] 2008. Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans

[25] ROYAL GOVERNMENT OF CAMBODIA 2010. Safety village commune/Sangkat Policy Guideline. Phnom Penh: Ministry of Interior

[26] YASAK, L., VANDA, K., BOR, H. & KHUNEARY, H. 2016. Enhancing Local Development of Commune/Sangkat in Battambong Province. Phnom Penh, Cambodia: Parliamentary Institute of Cambodia.

[27] SOKUNKOLYAN, T., PAUL, C. & SU, Y. Z. K. 2016. Addressing Marketing Problems of Farmers in Ratanakiri Province. Phnom Penh: Parliamentary Institute of Cambodia.

[28] Ibid.

[29] CHANREAKSMEIDARA, V., CHAMPANOOT, T., TERITH, C., DAVY, T., RANO, F. & SOKUNKOLYAN, T. 2016. Comparative Study: Anticorruption in the Context of Decentralisation &

Deconcentration in India, Thailand, Cambodia and Malaysia. Phnom Penh, Cambodia: Parliamentary Institute of Cambodia.

[30] សេចក្តីសន្និដ្ឋាននេះធ្វើឡើងដោយផ្អែកលើ ឯកសារ និងទិន្នន័យបន្ទាប់បន្សំ។ ដូច្នេះឯកសារស្រាវជ្រាវសង្ខេបនេះ តម្រូវឲ្យអ្នកស្រាវជ្រាវពិនិត្យលើផែនការអភិវឌ្ឍខេត្តបាត់ដំបង ប៉ុន្តែក្រុមស្រាវជ្រាវឯកសារសង្ខេបនេះមិនអាចរកបាននូវផែនការនេះដើម្បីយកមកពិនិត្យនោះទេ។